**មាត្រា ៦** : ទីកន្លែងធ្វើការរបស់គណៈកម្មាធិការព្រំដែនទូទៅនៅក្រសួងការពារជាតិ ។ ចំណែកឯគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ ធ្វើការនៅទីបញ្ជាការដ្ឋានកងការពារព្រំដែនអគ្គសេនាធិការ ។

**មាត្រា ៧** : គណៈកម្មាធិការព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។ ចំពោះគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

**មាត្រា ៨** : ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ ខែកុម្ភៈឆ្នាំ ១៩៩៥ ។

**មាត្រា ៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ ស្ថាប័នពាក់ព័ន្ធនិងសមាសភាពស្ថិតនៅក្នុង មាត្រា ១ , មាត្រា ២ , មាត្រា ៣ , ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ១០**: អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខា និងត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និង ត្រា**
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

## អនុក្រឹត្យ លេខ ៦៨ អនក្រ.បក
## ស្តីពីការបង្កើតមន្ទីរប្រឆាំងគ្រឿងញៀន

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

**សំរេច**

**មាត្រា ១ :** បង្កើតមន្ទីរប្រឆាំងគ្រឿងញៀន ។

មន្ទីរប្រឆាំងគ្រឿងញៀនមានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយស្ថិតនៅក្រោមឱវាទអគ្គនាយកដ្ឋាននគរបាលជាតិ ។

**មាត្រា ២ :** មន្ទីរប្រឆាំងគ្រឿងញៀនមានភារកិច្ចដូចតទៅ ÷

- ដឹកនាំ និង បញ្ជាកម្លាំងនគរបាលស្រាវជ្រាវពត៌មាន និង ចាត់វិធានការទប់ស្កាត់ និង បង្ក្រាបគ្រឿងញៀន ។
- សហការជាមួយនាយកដ្ឋាន និង ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ផ្តល់ពត៌មានដែលទាក់ទងនឹងគ្រឿងញៀន មកមន្ទីរប្រឆាំងគ្រឿងញៀន ដើម្បីចាត់វិធានការបង្ក្រាប ។
- ទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គយ) ក្រសួងការពារជាតិ (កងរាជអាវុធហត្ថ) ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងការបរទេស និង

សហប្រតិបត្តិការអន្តរជាតិ សមាគម និងស្ថាប័នផ្សេង ៗ ដើម្បីសហការប្រឆាំងនឹងគ្រឿងញៀន ។

-រៀបចំផែនការប្រឆាំងគ្រឿងញៀនស្របតាមគោលការណ៍អន្តរជាតិ និង តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់បង្ក្រាបគ្រឿងញៀន ។

-ចូលរួមប្រជុំ ស្តីអំពីការបង្ក្រាបគ្រឿងញៀននៅក្នុងប្រទេស និង ក្រៅប្រទេស ។

-រៀបចំកម្មវិធីហ្វឹកហ្វឺនកងកម្លាំងនគរបាលជាតិ អំពីការទប់ស្កាត់ និង បង្ក្រាបគ្រឿងញៀន ។

-អនុវត្តភារកិច្ចផ្សេង ៗ ទៀតពាក់ព័ន្ធនឹងគ្រឿងញៀន ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនប្រគល់អោយ ។

**មាត្រា ៣ :** ការរៀបចំជាក់ស្តែងនូវភារកិច្ច និង របនាសម្ព័ន្ធរបស់មន្ទីរប្រឆាំងគ្រឿងញៀន ត្រូវកំណត់ដោយប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥

## អនុក្រឹត្យ លេខ ៦៩ អនក្រ.បក

## ស្តីពីការបង្កើតសាលាកសិកម្មកំពង់ចាម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា